ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៥ អនក្រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតអង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេស ជាយន្តការអន្តរក្រសួងដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រធាន

| | | |
|---|---|---|
| ២- ឯកឧត្តម **សារុន ឫទ្ធា** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៣- ឯកឧត្តម **ហែម វណ្ណឌី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម **នុត អ៊ុនវ័ណ្ណា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៥- ឯកឧត្តម **លាង មុនីឫទ្ធិ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- ឯកឧត្តម **សុខ តុងហាប់** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- ឯកឧត្តម **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៨- លោកជំទាវ **ច័ន្ទ សូរីយ៍** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ៩- ឯកឧត្តម **សាត សមុទ្រ** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០-ឯកឧត្តម **អ៊ុក ប្រជា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១-ឯកឧត្តម **សៅ សុភាព** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១២-ឯកឧត្តម **ហ៊ាន វណ្ណហាន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣-ឯកឧត្តម **ខូវ មករា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៤-ឯកឧត្តម **ស៊ឹម ណារ៉ា** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ១៥-លោកជំទាវ **ហង់ លីណា** | អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ | សមាជិកា |
| ១៦-ឯកឧត្តម **វ៉ាន់ មុនីនាថ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | សមាជិក |
| ១៧-ឯកឧត្តម ឧកញ៉ា **ខួន ម៉េងតិច** | អគ្គនាយកនៃសភាពាណិជ្ជកម្មកម្ពុជា | សមាជិក។ |

អង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេសអាចមានសមាសភាពបន្ថែមទៀតតាមការចាំបាច់នៃការងារ។

**ប្រការ២ .-**

អង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេសមានភារកិច្ចដូចខាងក្រោម៖

- បំពេញភារកិច្ចជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស
- ចាត់ចែង សហការ និងសម្របសម្រួលថ្នាក់ជាតិសម្រាប់ការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស
- ដឹកនាំ ចង្អុលបង្ហាញ និងផ្តល់អនុសាសន៍ ក៏ដូចជាធ្វើការណែនាំអំពីការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស
- ធ្វើការណែនាំនិងផ្តល់ការតម្រង់ទិសស្របនឹងយុទ្ធសាស្ត្រសម្រាប់ការអនុវត្តកម្មវិធីភាពជាដៃគូប្រទេសនិងកំណត់អាទិភាពគម្រោងដើម្បីឱ្យកម្មវិធីភាពជាដៃគូប្រទេសអនុវត្តប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងមានថវិកាគ្រប់គ្រាន់
- ជំរុញនិងគាំទ្រឱ្យការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស ចូលរួមចំណែកដ៏សកម្មជាមួយគោលនយោបាយជាតិ និងបម្រើគោលដៅនៃកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងអនុវត្តតាមរបៀបវារៈនៃគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ក្នុងការជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ជាតិ

- លើកកម្ពស់និងសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរភ្នាក់ងារក្នុងក្របខ័ណ្ឌនៃកម្មវិធីភាពជាដៃគូប្រទេសដើម្បីបង្កើតភាពស៊ីសង្វាក់គ្នានិងបង្កើននូវប្រសិទ្ធភាពរបស់គម្រោង
- ផ្តល់ធាតុចូលសម្រាប់ការអភិវឌ្ឍនិងការបញ្ចប់នូវឯកសារគម្រោង ដោយផ្អែកលើលទ្ធភាពនិងធនធានថវិកាដែលមាន
- ផ្តល់ធាតុចូលសម្រាប់ការរៀបចំផែនការការងារប្រចាំឆ្នាំរបស់ដៃគូអនុវត្តដែលមានការពាក់ព័ន្ធ
- ផ្តល់ធាតុចូលសម្រាប់ការវាយតម្លៃឯករាជ្យដើម្បីធានាឱ្យការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស ទទួលជោគជ័យប្រកបដោយតម្លាភាព
- លើកទឹកចិត្តនិងគាំទ្រឱ្យមានការចូលរួមពីវិស័យសាធារណៈនិងឯកជនដែលមានការពាក់ព័ន្ធទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងឧស្សាហកម្ម
- ជំរុញឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍសំខាន់ៗក្នុងការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស ប្រកបដោយចីរភាពនិងភាពស៊ីសង្វាក់គ្នារវាងប្រតិបត្តិការជាក់ស្តែងនិងផែនការដែលបានគ្រោងទុក
- រៀបចំនិងបង្កើតឱ្យមានរចនាសម្ព័ន្ធគាំទ្រដល់ដំណើរការនៃការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស រួមទាំងការបង្កើតក្រុមការងារនិងការរៀបចំសេចក្តីព្រាងស្តីពីការរៀបចំលក្ខខណ្ឌការងារ
- រៀបចំផែនការសកម្មភាពនិងផែនការប្រតិបត្តិទាំងឡាយ រួមទាំងការត្រួតពិនិត្យប្រព័ន្ធហិរញ្ញវត្ថុនិងរបាយការណ៍ក្នុងការអនុវត្តកម្មវិធីភាពជាដៃគូប្រទេសរបស់ក្រុមការងារ
- ធានានូវការសម្របសម្រួលធនធានជាអតិបរមាអំពីការងារវិនិយោគសាធារណៈ កម្ចីពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនិងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់វិស័យធុរកិច្ច ស្របតាមគោលការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ស្វែងរកនិងកំណត់ដៃគូហិរញ្ញវត្ថុបន្ថែមដើម្បីធានានូវភាពជោគជ័យក្នុងការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស
- រៀបចំនិងធានាឱ្យកម្មវិធីភាពជាដៃគូប្រទេសស្របតាមគោលនយោបាយជាតិនិងគោលដៅកំណើនសេដ្ឋកិច្ចជាតិ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីភាពជាដៃគូប្រទេស រួមទាំងផ្តល់នូវយោបល់និងអនុសាសន៍ផ្សេងៗដល់ភាគីពាក់ព័ន្ធនិងរាជរដ្ឋាភិបាល
- ពិនិត្យរបាយការណ៍សកម្មភាពរបស់កម្មវិធីភាពជាដៃគូប្រទេសនិងផ្តល់ការណែនាំឬយោបល់ជាយុទ្ធសាស្ត្រដើម្បីធ្វើការកែតម្រូវណាមួយឱ្យមានលក្ខណៈសមស្របនិងមានប្រសិទ្ធភាព
- ពិនិត្យលើផែនការសកម្មភាពនៃកម្មវិធីភាពជាដៃគូប្រទេស ការចាត់ចែងការប្រើប្រាស់ធនធានមនុស្សហិរញ្ញវត្ថុដើម្បីតម្រង់ទិស និងការត្រួតពិនិត្យវាយតម្លៃដើម្បីមានមូលដ្ឋានជំរុញការអនុវត្តបន្ត
- កំណត់និងធ្វើអាទិភាពគម្រោង ព្រមទាំងចាត់ចែងធនធានសម្រាប់ផែនប្រតិបត្តិការរបស់កម្មវិធីភាពជាដៃគូប្រទេស
- ពិនិត្យ សិក្សាស្ថានភាពការអនុវត្តកម្មវិធីភាពជាដៃគូប្រទេសដើម្បីកែសម្រួលលក្ខខណ្ឌការងារតាមការចាំបាច់ដើម្បីឆ្លើយតបនឹងសំណូមពរនិងតម្រូវការ
- បំពេញការងារចាំបាច់ផ្សេងៗទៀតដែលមានចែងនៅក្នុងក្របខ័ណ្ឌការងារនៃកិច្ចព្រមព្រៀងរវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលជាតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការយូនីដូ( UNIDO )
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

**ប្រការ៣ ._**

អនុប្រធាននិងសមាជិកនៃអង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេសត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

សមាជិកត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តការងារដែលមានការពាក់ព័ន្ធដល់អង្គភាពឬស្ថាប័នរបស់ខ្លួន។

អង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេសមានសិទ្ធិប្រើត្រារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៤ ._**

អង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេសមានលេខាធិការដ្ឋានមួយជាសេនាធិការនិងមានទីតាំងនៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

សមាសភាពនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានអង្គភាពសម្របសម្រួលថ្នាក់ជាតិរបស់កម្មវិធីដើម្បីភាពជាដៃគូប្រទេស។

**ប្រការ៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ